**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :០៦៤.កយ.ប្រក/២៥

# ប្រកាស
## ស្តីពី
## ការកំណត់ឯកសណ្ឋានរបស់មន្ត្រីនៅតាមអង្គភាពរដ្ឋបាល នៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

## សម្រេច

### ប្រការ១ .- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់អំពីឯកសណ្ឋានរបស់មន្ត្រីនៅតាមអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។

### ប្រការ២ .- អំពីឯកសណ្ឋាន

ឯកសណ្ឋានរបស់មន្ត្រីនៅតាមអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ត្រូវកំណត់ដូចខាងក្រោម៖

- **អាវ** ៖ អាវសឺមី ដៃខ្លី ឬដៃវែង ពណ៌ខៀវ កឌុប ប៉ូលស្មាពីរសងខាង ហោប៉ៅពីរសងខាង មានគម្របស្លឹកពោធិ៍។
- **ខោ ឬសំពត់** ៖ ពណ៌ខ្មៅ ដែល៖
  - **សម្រាប់បុរស៖** ខោជើងវែង មានហោប៉ៅក្រោយមួយ មានគម្រប ហើយដេរបង្កប់ និងមានហោប៉ៅចំហៀងពីរ
  - **សម្រាប់នារី៖** សំពត់ស្វារ៉េ កាត់សម្រុងក្រោមជង្គង់ ឆែកពីក្រោយ ១៥ (ដប់ប្រាំ)សង់ទីម៉ែត្រ។
- **រូបសញ្ញាក្រសួងយុត្តិធម៌** ៖ សញ្ញាក្រសួងយុត្តិធម៌ស្ថិតក្នុងរង្វង់ផ្ទៃពណ៌ស ដែលមានអង្កត់ផ្ចិតទំហំ ០.៦ សង់ទីម៉ែត្រ ហើយមានឆ្លាក់អក្សរពីខាងលើ "**ព្រះរាជាណាចក្រកម្ពុជា**" និងអក្សរពីខាងក្រោម ៖ **១. អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល, ២. អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍, និង ៣. លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង** ដោយដេរភ្ជាប់នៅដៃអាវខាងស្តាំផ្នែកខាងលើ ឃ្លាតពីស្មា ១០ (ដប់)សង់ទីម៉ែត្រ។
- **ស្លាកឈ្មោះ** ៖ ធ្វើពីជ័រវីងក្លី ពណ៌ឈាមជ្រូក អក្សរពណ៌ទឹកមាស បកបិទលើហោប៉ៅអាវខាងឆ្វេង ដែល៖
  - នៅផ្នែកខាងឆ្វេងមានឆ្លាករូបសញ្ញាក្រសួងយុត្តិធម៌
  - រីឯផ្នែកខាងស្តាំមានឆ្លាកឈ្មោះជាអក្សរខ្មែរ អក្សរឡាតាំង និងអត្តលេខនៅពីក្រោម។

រូបគំនូរឯកសណ្ឋានរបស់មន្ត្រីនៅតាមអង្គភាពរដ្ឋបាលនៃសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ៣ .- ការប្រើប្រាស់ឯកសណ្ឋាន

មន្ត្រីនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ និងលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវស្លៀកពាក់ឯកសណ្ឋានមន្ត្រី ក្នុងការបំពេញការងារប្រចាំថ្ងៃ និងក្នុងពេលចុះបំពេញបេសកកម្ម។

### ប្រការ៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី១**

នៃប្រកាសលេខ ០៦៤.កយក. ប្រក/២៥ ចុះថ្ងៃទី ...១០...ខែ មេសា ...ឆ្នាំ២០២៥

ស្ដីពីឯកសណ្ឋានរបស់មន្ត្រីនៅតាមអង្គភាពរដ្ឋបាលនៃសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់

**គំរូសម្លៀកបំពាក់របស់មន្ត្រី នៅតាមអង្គភាពរដ្ឋបាលនៃសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់**

១.សម្លៀកបំពាក់ប្រភេទសីមី ប្រើសម្រាប់បំពេញការងារប្រចាំថ្ងៃ និងចុះបំពេញបេសកកម្ម

-ចំពោះបុរស (អាវដៃវែង និងអាវដៃខ្លី)



-ចំពោះនារី (អាវដៃវែង និងអាវដៃខ្លី)

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងយុត្តិធម៌



**ឧបសម្ព័ន្ធទី២**

១. គំរូអាវសម្រាប់បុរស



ព្រះរាជាណាចក្រកម្ពុជា
ក្រសួងយុត្តិធម៌

២. គំរូអាវសម្រាប់នារី



## ឧបសម្ព័ន្ធទី៣

១.ស្លាកឈ្មោះសម្គាល់ និងរូបសញ្ញាសម្គាល់នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល



២. ស្លាកឈ្មោះសម្គាល់ និងរូបសញ្ញាសម្គាល់នៃអគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍



៣. ស្លាកឈ្មោះសម្គាល់ និងរូបសញ្ញាសម្គាល់នៃលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

